កាលបរិច្ឆេទៈ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៧

# មេរៀនដំណាំត្រប់ស្រួយ

## I. ប្រវត្តិសង្ខេបនៃការដាំត្រប់ស្រួយ

ដំណាំត្រប់ស្រួយគឺជាដំណាំងាយស្រួលដាំ ហើយជាទូទៅកសិករភាគច្រើនចូលចិត្តយកវាមកធ្វើជាអន្លក់ឬបន្លែ និងយកវាមកស្ល ធ្វើជាម្ហូបសម្រាប់បរិភោគក៏បាន។

អាយុកាលរបស់ដំណាំត្រប់ស្រួយចាប់រាប់ តាំងពីពេលដាំរហូតដល់ថ្ងៃប្រមូលផលប្រហែលជា៥០ទៅ៦០ថ្ងៃប៉ុណ្ណោះអាចប្រមូលផលបាន។ បន្ថែមពីនោះ ដំណាំនេះអាចយកទៅធ្វើជាបន្លែសម្រាប់ហូប ឬសម្រាប់លក់ដូរនៅឯទីផ្សារក៏បាន។ ពូជដំណាំនេះ មិនរើសរដូវកាលដាំដុះឡើយ យើងអាចដាំវាបានគ្រប់រដូវកាល។

ដំណាំត្រប់ស្រួយត្រូវការកំដៅ ចាប់ពី៩០ទៅ១០០ភាគរយ សម្រាប់ជួយទ្រទ្រង់ដើមរបស់វា។ បន្ថែមពីនោះ វាក៏ត្រូវការទឹកនិងសំណើមត្រជាក់ជាប់ជាអចិន្ត្រៃយ៍ផងដែរ គឺនៅក្នុងពេលព្រឹកនិងពេលល្ងាច។

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

## II. គម្រោងដាំត្រប់ស្រួយ

យើងត្រូវរៀបចំគម្រោងសម្រាប់ដាំត្រប់ស្រួយដូចខាងក្រោម៖

១- ជាដំបូងជ្រើសរើសទីតាំងដីសម្រាប់ដាំដុះ

២- កាប់គាស់ភ្ជួររាស់និងហាលដីប្រហែល១សប្តាហ៍

៣- មានប្រភពទឹកសម្រាប់ប្រើប្រាស់

៤- មានពូជសម្រាប់ដាំដុះ

៥- ជាតិសម្រាប់ប្រើប្រាស់

៦-មានឧបករណ៍ពាក់ព័ន្ធដូចជា ចប ឡាំង បង្គី និងកម្លាំងអូសទាញ។ល។

៧-ចំណុចសំខាន់មួយទៀតគឺកម្លាំងពលកម្មសម្រាប់ថៃទាំនិងមានបច្ចេកទេសផងដែរ។

## III. វិធីសាស្ត្រ ឬបច្ចេកទេសនៃការដាំត្រប់ស្រួយ

យើងមានបច្ចេកទេសសម្រាប់ដាំត្រប់ស្រួយដូចខាងក្រោម៖

១- កាប់រណ្តៅក្នុងជម្រៅ២០សង់ទីម៉ែត្រ (២តឹក) ហើយជ្រុង នីមួយៗនៃមាត់រណ្តៅយកប្រវែង២៥សង់ទីម៉ែត្រស្មើ២តឹកកន្លះ បន្ទាប់ពីរៀបចំដីឱ្យបានល្អមក។

២- យកគ្រាប់ពូជមកខ្ចប់ជាមួយនឹងត្រណាត់ ហើយដាក់ត្រាំនៅក្នុងទឹកធុងរយៈពេល១យប់។

---

កាលបរិច្ឆេទៈ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៧

៣- ស្រង់គ្រាប់ពូជពីទឹក ហើយដាក់ផ្អាប់រយៈពេល១យប់ទៀតនៅក្នុង ធុងដែលមានជាតិសើម

៤- ច្របល់ជីធម្មជាតិឱ្យសព្វជាមួយនឹងដីនៅក្នុងរង

៥-យកគ្រាប់ពូជត្រប់ស្រួយមកសាបលើថ្នាលដែលបានរៀបចំជស្រេច

៦- នៅពេលកូនត្រប់មានអាយុ២៥ថ្ងៃ ដកវាមកដាក់ដាំក្នុងរណ្ដៅ

៧- ស្រោចទឹកដំណាំត្រប់ព្រឹកល្ងាចព្រមទាំងថែទាំវាជាប្រចាំ។

## បញ្ជាក់ពីចំណុចសំខាន់៖

- ការដាំត្រប់ស្រួយពីគុម្ពមួយទៅគុម្ពត្រូវទុកគម្លាតពីគ្នាប្រវែង១ម៉ែត្រ
- រណ្ដៅត្រប់នីមួយៗត្រូវជីក្នុងជម្រៅ២០សង់ទីម៉ែត្រឬ២តឹក
- ជាទូទៅ ទ្រូងរងសម្រាប់ផ្លូវដើរទុកចន្លោះពីមួយជួរទៅមួយជួរគម្លាតពីគ្នា១,៣ម៉ែត្រឬ១ម៉ែត្រ៣តឹក៕

**សូមអរគុណ**

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាឌីណាស់ (CRDNASE)

# មេរៀនដំណាំល្ពៅ

## I. ប្រវត្តិសង្ខេបនៃការដាំល្ពៅ

ដំណាំល្ពៅគឺជាដំណាំងាយស្រួលដាំបំផុតនៅក្នុងការដាំជាលក្ខណៈគ្រួសារ ឬដាំនៅក្នុងចម្ការធំៗក្តី ហើយវាក៏ជាដំណាំឆ្លងកាត់មួយប្រភេទដែលកសិករភាគច្រើនចូលចិត្តនិយមដាំនៅតាមសហគមន៍នានា។

### ១-អាយុកាលរបស់ដំណាំល្ពៅ

ពេលវេលាឬអាយុកាលរបស់ពូជដំណាំល្ពៅចាប់តាំងពីពេលការដាំដុះរួចមក បានអាយុប្រហែលត្រឹមតែ៨០ទៅ៨៥ថ្ងៃ យើងអាចប្រមូលផលវាបាននិងអាចយកវាទៅធ្វើជាបន្លែសម្រាប់ហូប ឬសម្រាប់លក់ដូរបានជាធម្មតា។ ពូជដំណាំនេះមិនរើសរដូវកាលដាំដុះទេ យើងអាចដាំវាបានគ្រប់រដូវកាល។

### ២-តម្រូវការកំដៅ

ដំណាំល្ពៅត្រូវការកំដៅឬពន្លឺថ្ងៃចាប់ពី៨០ទៅ១០០ភាគរយ ដើម្បីទ្រទ្រង់ដើមរបស់វា។ ម៉្យាងវិញទៀតវាក៏ត្រូវការទឹកនិងសំណើមព្រឹក

ល្ងាចផងដែរទើបធ្វើឱ្យវាឆាប់បានទទួលផល ប៉ុន្តែបើមានភ្លៀងធ្លាក់ជោគជាំហើយមិនចាំបាច់ស្រោចស្រប់វាទេ។

### ៣-ទីតាំងដាំដុះ

ទីតាំងដីសម្រាប់ដាំដំណាំល្ពៅគឺ ត្រូវដាំវាគេចឲ្យផុតពីដីទំនាប និងដីជោគជាំដោយសារទឹកភ្លៀងឬទឹកជំនន់។ ចំណុចសំខាន់សម្រាប់រដូវប្រាំងគឺមានប្រភពទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រប់គល់ និងឫសរបស់វាជាប្រក្រតី។

## II. គម្រោងដាំដំណាំល្ពៅ

មុនយើងដាំដំណាំល្ពៅយើងត្រូវរៀបចំគម្រោងដាំឱ្យបានល្អជាមុនសិន។ គម្រោងដាំទាំងនោះមានដូចតទៅ៖

១-ជ្រើសរើសទីតាំងដីដាំដុះ កាប់គាស់ភ្ជួររាស់ហាលដីឲ្យបានល្អជាមុន ប្រហែល១សប្តាហ៍។

២-មានប្រភពទឹកសម្រាប់ប្រើប្រាស់គ្រប់គ្រាន់

៣-មានពូជដែលមានគុណភាពល្អ

៤-មានជីធម្មជាតិសម្រាប់ប្រើប្រាស់

៥-មានឧបករណ៍ពាក់ព័ន្ធដូចជាចប ឡាំង បង្គី កម្លាំងអូសទាញ។ល។

៦-ចំណុចសំខាន់គឺមានកម្លាំងពលកម្មសម្រាប់ថែទាំជាប្រចាំ។

## III. វិធីសាស្ត្របច្ចេកទេសដាំពូជល្ពៅ

១-ធ្វើការកាប់គាស់ ភ្ជួររាស់ និងហាលដីឲ្យបាន១អាទិត្យជាមុន។ គោលបំណងធ្វើដូច្នេះគឺដើម្បីសម្លាប់មេរោគដែលមាននៅក្នុងដីឲ្យអស់ និងសារធាតុពុលផ្សេងៗទៀត។ល។

២-ជីករណ្ដៅដាំគឺយកខ្នាតមាត់រណ្ដៅលើយកប្រវែង៣តឹក ឬ៣០សង់ទីម៉ែត្រ រីឯជម្រៅយកប្រវែង២តឹកកន្លះ ឬ៣តឹកក៏បាន។

៣-ត្រូវប្រើជីធម្មជាតិដែលមានស្រាប់ ក្នុង១រណ្ដៅយ៉ាងហោចណាស់អាចប្រើជី២គីឡូក្រាម (ត្រូវច្របល់វាក្នុងរណ្ដៅឲ្យសព្វ)។

៤-ត្រូវរៀបចំដាក់ត្រើងឲ្យវារឡើងនៅពេលល្ពៅដុះបានកំពស់ ៤សង់ទីម៉ែត្រពីមាត់រណ្ដៅ។

៥-បញ្ជាក់ពីវិធីធ្វើរណ្ដៅដាំ៖ មាត់រណ្ដៅខាងលើត្រូវយកប្រវែង៣០សង់ទីម៉ែត្របួនជ្រុង រីឯជម្រៅបាតរណ្ដៅវិញយកប្រវែង២តឹកកន្លះ ឬ៣តឹកជាការប្រសើរ។

៦-មុនដាំត្រូវយកពូជមកខ្ចប់ជាមួយនឹងក្រណាត់ហើយដាក់ត្រាំនៅក្នុងទឹកធុងរយៈពេល១យប់ដោយបិតគំរបធុងឲ្យជិតនោះជាការស្រេច។

៧-យកពូជមកដាំ ក្នុង១រណ្ដៅត្រូវប្រើពូជ៣គ្រាប់ រីឯជម្រៅនៃការកប់គ្រាប់ដាំវិញ យកជម្រៅ២ថ្នាំងដៃជាការគ្រប់គ្រាន់។

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

៨-ស្រោចទឹកព្រឹកល្ងាចនិងថែទាំជាប្រចាំ ចំណុចទាំងនេះវាជាកត្តាសំខាន់និងល្អបំផុតសម្រាប់ជំនាញលើការដាំដុះ។

៩-បែងចែកនៃគម្លាតជួរ គឺដាំពីគុម្ពមួយទៅគុម្ពមួយអាចចោលគម្លាតពីគ្នាប្រវែង១ម៉ែត្រ៣តឹក។

១០-គម្លាតនៃចន្លោះទ្រូងជួរ គឺត្រូវចោលចន្លោះពីគ្នាប្រវែង៣ម៉ែត្រកន្លះជាការគ្រប់គ្រាន់។

១១-បញ្ជាក់ពីការសង់ត្រើង៖ ទទឹងយកប្រវែង៤ម៉ែត្រ បណ្តោយយក៧ម៉ែត្រ (តាមលទ្ធភាពក៏បាន) ចំណែកឯកំពស់ត្រើងយកកំពស់១ម៉ែត២តឹកជាការគ្រប់គ្រាន់។

១២-ទីតាំងដីដាំដុះ គឺត្រូវគេចឲ្យផុតពីដីទំនាប និងភាពជោគជាំដោយសារទឹកភ្លៀងឬទឹកជំនន់។

១៣-ចំណុចពិសេសរបស់ដំណាំល្ពៅ៖ សូមចំណាំថាដំណាំល្ពៅអាចដាំដាក់ត្រើងក៏បានមិនចាំបាច់ដាក់ត្រើងក៏បាន តែបើដាំដាក់ត្រើងផ្លែល្ពៅបានល្អជាងផ្លែដែលនៅផ្ទាល់នឹងដី៕

**សូមអរគុណ**

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)